ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១០/២០ - ស្យុង យិន

កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ ទូន ស៊ីផាន់

ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ រុន សារ៉ាយ

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ថេកស្ទាយ ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិព្រែកគ្រែង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ព្ទ ៖ ០១២ ៩៧៦ ៧៥៨ ទូរសារ ៖ គ្មាន

-តំណាងភាគីនិយោជកចូលរួមសវនាការ ៖

១- លោក គុំ គីមសឿន ប្រធានរដ្ឋបាល

-តំណាងភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន ៖

១- លោក គុំ គីមសឿន ប្រធានរដ្ឋបាល

២- លោក សាន ឡាយ ជំនួយការរដ្ឋបាល

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ថិកស្ទាយ ខូអិលធីឌី**

អាសយដ្ឋាន ៖ ភូមិព្រែកគ្រែង សង្កាត់សិត្បូ ក្រុងតាខ្មៅ ខេត្តកណ្តាល

ទូរស័ពទ្ទ ៖ ០៨៧ ៧៧៧ ៨១៩ /០៦៩ ៣១ ១៧ ១០ ទូរសារ ៖ គ្មាន

-តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ ៖

១- លោក ស៊ាង យ៉ូត មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា

២- លោក គ្រេន ជឿន ប្រធាន (សហជីពមូលដ្ឋាន)

| | |
|---|---|
| ៣- លោក ទូន ណៃឡេង | អនុប្រធាន (សហជីពមូលដ្ឋាន) |
| ៤- លោក សំរ៉ុង បូរី | លេខាធិការ (សហជីពមូលដ្ឋាន) |
| ៥- លោកស្រី រី ស៊ីម៉ន | ហិរញ្ញិក (សហជីពមូលដ្ឋាន) |
| ៦- លោក សៃ សាន | ទីប្រឹក្សា |
| ៧- លោកស្រី វណ្ណ សុផា | សកម្មជន |
| ៨- លោក ញ៉ែប ថន | សកម្មជន |
| ៩- លោកស្រី ម៉ាក ផល្លី | សកម្មជន |
| ១០- កញ្ញា ម៉ៃ ស្រីរ៉ុង | សកម្មជន |
| ១១- លោកស្រី លី សុខហ៊ាង | សមាជិក |
| ១២- លោកស្រី យូ ប្រាន់ | សមាជិក |
| ១៣- លោកស្រី ហួន ស្រីខ្មែន | សមាជិក |
| ១៤- លោកស្រី ថន ប៉ុច | សមាជិក |

-តំណាងភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន ៖

| | |
|---|---|
| ១- លោក ស៊ាង យ៉ូត | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ២- លោក ស៊ី វ៉ាន់ធា | មន្ត្រីសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា |
| ៣- ទូន ណៃឡេង | អនុប្រធាន (សហជីពមូលដ្ឋាន) |
| ៤- លោក សំរ៉ុង បូរី | លេខាធិការ (សហជីពមូលដ្ឋាន) |
| ៥- លោក សៃ សាន | ទីប្រឹក្សា |
| ៦- លោកស្រី រី ស៊ីម៉ន | ហិរញ្ញិក |
| ៧- កញ្ញា សុខ សាមុត | សកម្មជន |
| ៨- លោកស្រី វណ្ណ សុផា | សកម្មជន |
| ៩- លោក ញ៉ែប ថន | សកម្មជន |
| ១០- លោកស្រី ផត ធីតា | សកម្មជន |
| ១១- លោកស្រី សុត រស់ | សមាជិក |
| ១២- លោក ឡាក់ ចំណាន | សមាជិក |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ទាមទារឱ្យនិយោជកបើកប្រាក់រំលឹកអតីតភាពការងារ និងប្រាក់បំណាច់អតីតភាពការងារ ជូនកម្មករនិយោជិត។

២- ទាមទារឱ្យនិយោជកសងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិត ករណីព្យួរការងារមិនត្រឹមត្រូវ ដែលគ្មានការអនុញ្ញាតពីអធិការការងារ។

៣- ទាមទារឱ្យនិយោជកទទួលយកសមាជិកសហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ថេកស្តាយ ខូអិលធីឌី ចូលធ្វើការងារវិញ និងសងរំលឹកប្រាក់ឈ្នួល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ចាប់ពីក្រុមហ៊ុនបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការងារវិញ។

៤- ទាមទារឱ្យនិយោជកសងរំលឹកប្រាក់ឈ្នួលព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករ ១២នាក់ ដែលមានក្នុងសំណុំរឿងលេខ ០៣៣/១៨-ស្យុង យិន (ខេមបូឌា) ប៊ី ថេកស្តាយ ខូអិលធីឌី។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ស្យុងយិន (ខេមបូឌា) ប៊ី ថិកស្តាយ ខូអិលធីឌី លេខ ១៣៤/២០ ក.ប/កណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ** ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យតន្ត្រីទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ** ៖ ថ្ងៃសុក្រ ៦រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**កាលបរិច្ឆេទផ្តល់ព័ត៌មាន** ៖ ថ្ងៃចន្ទ ២កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣
ត្រូវនឹងថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៥ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី៩ ខែមករា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ថិកស្តាយ ស្តីពីការទាមទារឱ្យក្រុមហ៊ុនកែលំអលក្ខខណ្ឌការងារចំនួន ៥ចំណុច ជូនកម្មករនិយោជិត។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់មន្ត្រីជំនាញឱ្យដោះស្រាយវិវាទការងារនេះ ទៅតាមនីតិវិធីច្បាប់ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ១ចំណុច។ ចំណុចមិន

THE ARBITRATION COUNCIL

សះជាដែលនៅសល់ចំនួន ៤ចំណុច ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី ៣០ ខែមករា ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្ដីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ស៊្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ លេខ ១៣៤/២០ ក.ប/កណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្ដាលត្រូវបានបង្កើតឡើងនៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សាលើចំណុចវិវាទមិនសះជានេះ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ នៅថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០២០ ភាគីនិយោជកបានស្នើសុំពន្យារពេលសវនាការ ទៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមូលហេតុរវល់រៀបចំបើកប្រាក់ឈ្នួលជូនកម្មករនិយោជិត។ ដោយពិចារណាលើមូលហេតុរបស់ភាគីនិយោជក ក្រុមអាជ្ញាកណ្ដាលសម្រេចលើកពេលសវនាការ ទៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខា-ធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានព្យាយាមស្វែរកនូវអង្គហេតុផ្សេងៗដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាទាំង ៤ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នាទេ។

ក្រោយថ្ងៃសវនាការអាជ្ញាកណ្ដាល ភាគីនិយោជកបានផ្ញើរូបភាព និងវីដេអូ ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ ដែលក្នុងនោះបង្ហាញអំពីសកម្មភាពរបស់ភាគីកម្មករនិយោជិតនៅច្រកចេញ ចូល នៃក្រុមហ៊ុន ហើយនិយោជកបានកំណត់សកម្មភាពនេះ ថាជាកូដកម្ម។ នៅថ្ងៃដដែល លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានទំនាក់ទំនងទៅភាគីកម្មករនិយោជិត ដើម្បីសាកសួរព័ត៌មានបន្ថែម ភាគីកម្មករនិយោជិតបានឆ្លើយតបថា ករណីនេះ មិនមែនជាសកម្មភាពកូដកម្មទេ។ ដោយហេតុថា អង្គហេតុមួយចំនួនដែលភាគីទាំងពីរបានលើកឡើងមានភាពខុសគ្នា ក្រុមប្រឹក្សាអាជ្ញាកណ្ដាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសាកសួរព័ត៌មានបន្ថែម ក្នុងកិច្ចប្រជុំក្រោយសវនាការអាជ្ញាកណ្ដាល នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ៣ និង ០០ នាទី រសៀល។ នៅក្នុងកិច្ចប្រជុំក្រោយសវនាការអាជ្ញាកណ្ដាល ភាគីនិយោជក និងភាគីកម្មករនិយោជិតមានវត្តមាន តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល។ នៅក្នុងកិច្ចប្រជុំក្រោយសវនាការអាជ្ញាកណ្ដាលនេះ ភាគីនិយោជកបានបញ្ជាក់ថា កម្មករនិយោជិតបានធ្វើសកម្មភាពរាំងរថយន្តដឹកសម្ភារៈរបស់ក្រុមហ៊ុនផ្សេង ដែលបានជួលទីតាំងក្នុងបរិវេណក្រុមហ៊ុន ស៊្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ នៅច្រកចេញ ចូល នៃក្រុមហ៊ុន ចាប់តាំងពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ ២០២០ រហូតមកដល់ថ្ងៃប្រជុំក្រោយសវនាការនេះដែរ។ ដោយឡែក ភាគីកម្មករនិយោជិតលើកឡើងថា ភាគីកម្មករនិយោជិតធ្វើសកម្មភាពបែបនេះ ព្រោះ ភាគីនិយោជកជំពាក់ប្រាក់ឈ្នួល ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងាររបស់ភាគីកម្មករនិយោជិត ហើយសកម្មភាពនេះ មិនត្រូវចាត់ទុកថា ជាកូដកម្មនោះទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមថា រថយន្តដឹកសម្ភារៈ គឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ស៊្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ មិនមែនជាកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេងនោះទេ។

នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ភាគីនិយោជកបានដាក់កំណត់ហេតុរបស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្មបាតុកម្មនៅតាមគ្រប់មុខសញ្ញា ស្ដីពីការប្រជុំករណីក្រុមហ៊ុនតម្បាញ ស៊្យុងយិន (ខេមបូឌា)

បីចិកស្ពាយ៍ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមានខ្លឹមសារ "*...II-សកម្មភាពកូដកម្ម បាតុកម្ម បងប្អូនកម្មករនិយោជិត អង្គុយនៅក្នុងរោងផ្ញើកង់ ម៉ូតូ*"។

ដូច្នេះក្រុមប្រឹក្សាអាជ្ញាកណ្ដាលធ្វើការពិចារណា ដូចខាងក្រោម៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្ដាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតរបស់ក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ គោរពជូន លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្ដាល ស្ដីពីសុំពន្យាពេលចូលរួមសវនាការ (សំណុំរឿងលេខ ០១០/២០) ចុះថ្ងៃអង្គារ ១១កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

២- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤៨ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។

៣- របាយការណ៍ស្ដីពីការញុះញង់ធ្វើកូដកម្ម រារាំង និងបិទទ្វារច្រកចេញ ចូល របស់ក្រុមហ៊ុន ចុះថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ របស់ក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ ខូអិលធីឌី។

៤- កំណត់ហេតុស្ដីពីការប្រជុំករណីក្រុមហ៊ុនតម្បាញ ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ ធ្វើនៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- លិខិតចាត់តាំងលោក ស៊ាង យ៉ូត ជាមន្ត្រីដោះស្រាយវិវាទរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីអមសម្របសម្រួលលើករណីដោះស្រាយវិវាទក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ លេខ ០១៣/២០ វិវាទ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- លិខិតពឹងពាក់ និងប្រគល់សិទ្ធិ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ របស់កម្មករនិយោជិត នៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ សូមពឹងពាក់ និងប្រគល់ សិទ្ធិជូនលោក គង់ អាទិត្យ ជាប្រធានសម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា ដើម្បីធ្វើជាតំណាងក្នុងការដោះស្រាយវិវាទការងាររួម។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈរបស់សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ លេខ ០០១៥/១៨ ក.ប/កណ ចុះថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨។

៤- លិខិតលេខ ០០១៥/១៨ ក.ប/កណ ចុះថ្ងៃអង្គារ ១៤កើត ខែមាឃ ឆ្នាំរកា នព្វស័ក ពស ២៥៦១ ត្រូវនឹងថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៨ របស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ បញ្ជាក់ថា សហជីពប្រជាធិបតេយ្យកម្មករនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្ពាយ៍ ជាអង្គការវិជ្ជាជីវៈមួយត្រូវបានចុះបញ្ជីនៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្ត

ARBITRATION COUNCIL

កណ្តាល និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ ចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះ តទៅ។

៥- ពាក្យបណ្តឹងរបស់កម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍ ចុះថ្ងៃពុធ ១៤កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ស្តីពីស្នើជួយអន្តរាគមន៍ ឱ្យនិយោជកក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍ ដោះស្រាយនូវ ការទាមទាររបស់កម្មករនិយោជិត។

៦- ញត្តិទាមទារ និងចាត់តាំងអ្នកតំណាង ចុះថ្ងៃពុធ ១៤កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ របស់កម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍។

៧- កំណត់ហេតុស្តីពីការសាកសួរព័ត៌មានពីតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍ ធ្វើនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០។

៨- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០២០។

៩- បញ្ជីឈ្មោះកម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍។

១០-លិខិតលេខ ០១៤/២០ ស.ប.ក/វិវាទ ចុះថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០ របស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា គោរពជូន លោក/លោកស្រីក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារលើសំណុំរឿង លេខ ០១០/២០-ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍។

១១- បញ្ជីឈ្មោះសមាជិកសហជីពបង់ភាគទាន។

១២- កំណត់ហេតុស្តីពីការទាមទារចូលធ្វើការវិញ និងសងរំលឹកប្រាក់ឈ្នួល ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០។

១៣- ប័ណ្ណសម្គាល់ខ្លួនកម្មករនិយោជិតក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍ របស់កម្មករឈ្មោះ គ្រេន ជឿន។

១៤- ប័ណ្ណសម្គាល់ថ្នាក់ដឹកនាំរបស់សម្ព័ន្ធសហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា របស់កម្មករឈ្មោះ គ្រេន ជឿន។

១៥- ប័ណ្ណសមាជិក ប.ស.ស។

១៦- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ របស់ឈ្មោះ គ្រេន ជឿន។

១៧- ប័ណ្ណបើកប្រាក់ខែ។

១៨- បញ្ជីរាយនាមកម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្តាយ៍ដែលដល់កុងត្រានៅក្នុងខែធ្នូ ឆ្នាំ២០១៩។

ARBITRATION COUNCIL

១៩- បញ្ជីរាយនាមកម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្គាយ៍ ដែលដល់កុងត្រានៅក្នុងខែមករា ឆ្នាំ២០២០។

២០- បញ្ជីរាយនាមកម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្គាយ៍ ដែលដល់កុងត្រានៅក្នុងខែកុម្ភៈ ឆ្នាំ២០២០។

២១- បញ្ជីឈ្មោះសហជីពផ្នែកអនាម័យ និងជាងភ្លើង។

២២- ប័ណ្ណសម្គាល់ខ្លួនកម្មករនិយោជិតនៃក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្គាយ៍។

២៣- វេជ្ជបញ្ជារបស់វេជ្ជបណ្ឌិត សរ ស៊ីសត្យា និងសៀវភៅសុខភាពរបស់មាតារបស់ឈ្មោះ ធី លីដា។

២៤- ប័ណ្ណសម្រាប់ណាត់ជួបអតិថិជនដើម្បីផ្តល់ប្រឹក្សា ។

២៥- ប័ណ្ណអនុញ្ញាតងោយចេញពីមន្ទីរពេទ្យលេខ ៣១២/១២/២០១៩ របស់មន្ទីរពេទ្យបង្អែកស្អាង។

២៦- វេជ្ជបញ្ជារបស់មន្ទីរពេទ្យកុមារគន្ធបុប្ផា។

២៧- លិខិតបញ្ជាក់កំណើតចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩ របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

២៨- លិខិតបញ្ជាក់កំណើតលេខ ០២/១៩ ម.ក.ស ចុះថ្ងៃព្រហស្បតិ៍ ៨កើត ខែបុស្ស ឆ្នាំកុរ ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០២ ខែមករា ឆ្នាំ២០២០ របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

២៩- លិខិតចេញពីមណ្ឌលសុខភាពលេខ០២/១៩ ម.ក.ស ចុះថ្ងៃអាទិត្យ ១១កើត ខែបុស្ស ឆ្នាំកុរ ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែមករា ឆ្នាំ២០២០ របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៣០- ប័ណ្ណអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យលេខ ៤៧២៥១/១០ ក.ប របស់ មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៣១- លិខិតបញ្ជាក់ពីការសំរាលកូនលេខ ២០១១ ឆ្នាំ២០១៩ របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៣២- សៀវភៅសុខភាពមាតារបស់ឈ្មោះ ហ៊ួត ស្រីឡែន។

៣៣- សៀវភៅសុខភាពមាតារបស់ឈ្មោះ ម៉ាក ផល្លី។

៣៤- សៀវភៅសុខភាពមាតារបស់ឈ្មោះ គយ សុខនឿន។

៣៥- សៀវភៅសុខភាពមាតារបស់ឈ្មោះ គយ ផុល។

៣៦- សៀវភៅសុខភាពមាតារបស់ឈ្មោះ ហេង លក្ខិណា។

៣៧- លិខិតបញ្ជាក់ពីការសំរាលកូនលេខ ០៣៣៨ ឆ្នាំ២០២០ របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៣៨- ប័ណ្ណអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យលេខ ៤៩៥៨៨/០២ ក.ប របស់ មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៣៩- សៀវភៅសុខភាពមាតារបស់ឈ្មោះ យូ ប្រាន់។

៤០- ប័ណ្ណអនុញ្ញាតឱ្យចេញពីមន្ទីរពេទ្យលេខ ១១៧/១២ ក.ប របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៤១- លិខិតបញ្ជាក់សុខភាពលេខ ២៩៧/២០១៩ របស់មន្ទីរសុខាភិបាលខេត្តកណ្ដាល។

៤២- លិខិតបញ្ជាក់ពីការសំរាលកូន។

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល THE ARBITRATION COUNCIL

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ស៊ុងយិន (ខេមបូឌា) ប៊ី ចិកស្ដាយ ខូអិលធីឌី លេខ ១៣៤/២០ ក.ប/កណ ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ស៊ុង យិន (ខេមបូឌា) ប៊ី ចិកស្ដាយ ខូអិលធីឌី ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ស៊ុង យិន (ខេមបូឌា) ប៊ី ចិកស្ដាយ ខូអិលធីឌី លេខ ០០៤/២០ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៤៧ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៤៨ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៥២ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១២ កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០២០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៥៣ កប/អក/វក/លកអ. ចុះថ្ងៃចន្ទ ១០កើត ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០។

៥- លិខិតអញ្ជើញភាគីនិយោជកចូលរួមផ្តល់ព័ត៌មាន លេខ ០៧២ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២០។

៦- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមផ្តល់ព័ត៌មាន លេខ ០៧៣ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ ២០២០។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើអង្គហេតុដែលភាគីទាំងពីរបានបញ្ជាក់ក្នុងសវនាការ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ នោះទេ។ *(សូមមើលបន្ថែមនៅក្នុងហេតុផលនៃសេចក្តីសម្រេច)*

## ហេតុផលនៃសេចក្តីសម្រេច ៖

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើត្រូវបន្តនីតិវិធីអាជ្ញាកណ្តាល ដែរឬទេ?

ប្រការ២០ នៃប្រកាសលេខ ០៩៩ សកបយ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ (តទៅនេះហៅថា ប្រកាសលេខ ០៩៩)ចែងថា៖ "*ក្នុងអំឡុងពេលនៃដំណើរការរបស់ក្រុមអាជ្ញាកណ្តាល ភាគីវិវាទទាំងឡាយត្រូវ*

*ផ្អាកពល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ(ដូចមានចែងក្នុងមាត្រា ៣១៨ នៃច្បាប់ស្តីពីការងារ) ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ។ ភាគីទាំងនេះ ត្រូវតែចូលរួមគ្រប់កិច្ចប្រជុំទាំងឡាយដែលក្រុមអាជ្ញាកណ្តាលបានអញ្ជើញឱ្យចូលរួម"។*

យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបកស្រាយថា ភាគីវិវាទត្រូវផ្អាករាល់វិធានការវិវាទ ដូចជាកូដកម្ម ឬឡុកអៅ ឬវិធានការដទៃទៀត ដែលអាចធ្វើឱ្យស្ថានភាពវិវាទកាន់តែធ្ងន់ធ្ងរ នៅក្នុងដំណើការអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបន្តដំណើរការអាជ្ញាកណ្តាលទេ នៅពេលណាកម្មករនិយោជិតកំពុងធ្វើកូដកម្ម ឬនិយោជកធ្វើឡុកអៅ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ៥៩/០៦-សាង៉ូ, លេខ ៣៩/០៨-ចុងយ៉ូវ, លេខ១៣៧/០៩&១៣៨/០៩-ញ៉ូកាញ់, លេខ ១១០/១១-ស៊ីម៉ាណូ, លេខ ១០៤/១៣-សាប្រ៊ីណា (ខេមបូឌា), លេខ ៣២២/១៤-ជីមលី(ខេមបូឌា) ភីជីអុី អិលធីឌី, លេខ ០៧១/១៥-អ៊ឹម រ៉េ កាត់ដេរ អន្តរជាតិ សាខាកំពង់ផ្ទាំង, លេខ ០២១/១៦-ស្ការឡែប៍ អីកែរីលេ មេនូហ្វេកធើរីង, លេខ ០៤៥/១៦-ក្លូប័លអាប៉ារែលលីមីធីត, លេខ ០៤៩/១៧-ហ្គារ៉ន្តែ អីកែរីល ខូអិលធីឌី, លេខ ០៥៦/១៨-ដាប់ប៊ីលយូអែនដ៍ឌី (កម្ពុជា) ខូអិលធីឌី និងលេខ ០០៨/១៩-ឥណ្ឌូចិន អីកែរីល (ខេមបូឌា) អិលធីឌី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ។

ករណីនេះ ក្រោយពីបានបញ្ចប់សវនាការអាជ្ញាកណ្តាល ដើម្បីសួររកអង្គហេតុ រួចមក នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២០ លេខាធិការដ្ឋានបានទទួលដំណឹងពីភាគីនិយោជកថា កម្មករនិយោជិតបានចេញក្រៅរោងចក្រ ដើម្បីធ្វើកូដកម្ម និងបិទច្រកចេញចូល មិនឱ្យរថយន្តដឹកសម្ភារះរបស់ក្រុមហ៊ុនផ្សេងចេញចូលទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីទាំងពីរមកចូលរួមកិច្ចប្រជុំក្រោយសវនាការអាជ្ញាកណ្តាល នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ៣ និង ០០ នាទី រសៀល ដើម្បីសួរនាំពីព័ត៌មានកូដកម្ម។

យោងតាមអង្គហេតុ ក្នុងកិច្ចប្រជុំក្រោយសវនាការអាជ្ញាកណ្តាល ភាគីនិយោជកបានលើកឡើងថា ចាប់តាំងពីថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០ រហូតមកដល់ថ្ងៃកិច្ចប្រជុំក្រោយសវនាការអាជ្ញាកណ្តាល ភាគីកម្មករនិយោជិតបានធ្វើកូដកម្ម ដោយរាំងរថយន្តដឹកសម្ភារះរបស់ក្រុមហ៊ុនផ្សេង ដែលជួលទីតាំងក្នុងបរិវេណក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ មិនឱ្យចេញពីបរិវេណក្រុមហ៊ុនទេ។ ដោយឡែក ភាគីកម្មករនិយោជិតលើកឡើងថា កម្មករនិយោជិតធ្វើសកម្មភាពបែបនេះ ព្រោះភាគីនិយោជកជំពាក់ប្រាក់ឈ្នួល ប្រាក់បំណាច់អតីតភាពការងារ និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងាររបស់ភាគីកម្មករនិយោជិត ហើយសកម្មភាពនេះ មិនត្រូវចាត់ទុកថា ជាកូដកម្មនោះទេ។ ភាគីកម្មករនិយោជិតបានបញ្ជាក់បន្ថែមថា រថយន្តដឹកសម្ភារះ គឺជាកម្មសិទ្ធិរបស់ក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ មិនមែនជាកម្មសិទ្ធិរបស់ក្រុមហ៊ុនផ្សេងនោះទេ។

យោងតាមកំណត់ហេតុរបស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហា កូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ស្តីពីការប្រជុំករណីក្រុមហ៊ុនតម្បាញ ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២០ លោក សយ សុភាព ជាអនុប្រធានផ្នែកអន្តរាគមន៍ និងដោះស្រាយទី៤ នៃគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា បានបើកកិច្ចប្រជុំស្វែងរកដំណោះស្រាយ ជូនភាគីទាំងពីរ និងបានកំណត់សកម្មភាពរបស់កម្មករនិយោជិតអង្គុយនៅក្នុងរោងផ្ញើកង់ និងម៉ូតូ ថាជាសកម្មភាពកូដកម្ម។ យោងតាមប្រការ ២០ នៃប្រកាសលេខ ០៩៩ និងភស្តុតាងជាកំណត់ហេតុរបស់គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ភាគីកម្មករ

និយោជិតបានធ្វើសកម្មភាពកូដកម្ម នៅក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍ នៅក្នុងដំណើរការអាជ្ញាកណ្តាល ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនបន្តដំណើរការអាជ្ញាកណ្តាល នៅពេលកម្មករនិយោជិតកំពុងបន្តធ្វើកូដកម្មដូចនេះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ។

យោងតាមអង្គច្បាប់ និងហេតុផលដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច

- បញ្ចប់ដំណើរការអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០១០/២០-ក្រុមហ៊ុន ស្យុង យិន (ខេមបូឌា) ប៊ី ចិកស្លាយ៍។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **អ៊ឹម សុទ្ធី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **ទួន ស៊ីផាន់**

ហត្ថលេខា ៖------------------------------

**ប្រធានក្រុមអាជ្ញាកណ្តាល ៖**

ឈ្មោះ៖ **រុន សារ៉ាយ**

ហត្ថលេខា ៖ ------------------------------

ក្រុមប្រឹក្សាអាជ្ញាកណ្តាល

THE ARBITRATION COUNCIL